# «រោគគ្រុនបក្សីនៅក្នុងសហរដ្ឋអាមេរិក»
## ខ្សែភាពយន្តនៅក្នុងទូរទស្សន ABC ប៉ុស្តិ៍លេខ 5
## ABC Television Movie "Fatal Contact: Bird Flu in America"
## 8:00 PM Eastern Time, May 9, 2006

អស់លោក-លោកស្រី កាលពីថ្ងៃអង្គារ៍ ទី 9 ខែ ឧសភា ឆ្នាំ 2006 កន្លងមកនេះ ទូរទស្សន៍ ABC ប៉ុស្តិ៍លេខ 5 បានផ្សាយភាពយន្តមួយហៅថា រឿង «រោគគ្រុនបក្សីនៅក្នុងសហរដ្ឋអាមេរិក»។ ភាពយន្តនេះ យកលំនាំតាមការរាតត្បាតនៃមេរោគវ៉ៃរ៉ើស H5N1 ដែលមាននៅក្នុងទីក្រុង ហុងកុង ហើយដែលក្លាយទៅជាឆ្លងដល់មនុស្ស និងរាតត្បាតយ៉ាងឆាប់រហ័សពេញពិភពលោក។

លំដាប់តទៅនេះជាចំណុចសំខាន់ៗខ្លះ នៃខ្សែភាពយន្ត ដែលបុគ្គលិកនៅក្រសួងសុខភាពនិងមនុស្សធម៌ ហៅថា  U.S. Department of Health and Human Services នៃសហរដ្ឋអាមេរិក បានមើលហើយស្រង់យកមកពិភាក្សា ហើយដែលអស់លោក-លោកស្រីគួរជ្រាបឲ្យអំពីការពិតនៃរោគគ្រុនបក្សី៖

- រឿង «រោគគ្រុនបក្សីនៅក្នុងសហរដ្ឋអាមេរិក» ក្នុងទូរទស្សន ABC ជាខ្សែ ភាពយន្ត។ ពុំមែនជា រឿងឯកសារនោះទ្បើយ។  វាជាផលិតកម្មដែលចងក្រងឡើងសំរាប់បំពេរកំដរអារម្មណ៍អ្នកមើល ហើយដែលពុំមានលក្ខណពិតប្រាកដស្របទៅតាមហេតុការណ៍ដែលកើតឡើងក្នុងពិភពលោកនោះឡើយ។
- ក្នុងពេលបច្ចុប្បន្ននេះ គឺនៅពុំទាន់មានការរាតត្បាតក្នុងពិភពលោកឡើយ។
- ម្យ៉ាងទៀត ជាការមួយសំខាន់ គួរជ្រាបថា មេរោគ H5N1 កើតសឹងតែ ចំពោះសត្វបក្សីប៉ុណ្ណោះ។ គេពុំទាន់រកឃើញមេរោគ H5N1 នៅក្នុងសហរដ្ឋអាមេរិកនៅឡើយទេ។
- ប្រសិនបើមានមេរោគនេះក្នុងសហរដ្ឋ ក៏ពុំមែនបានន័យថា វាចាប់ផ្តើមរាតត្បាតរង្គាលភ្លាមនោះដែរ។
- នៅពេលដែលខ្សែភាពយន្តលេងអំពីការរាតត្បាតនៃរោគគ្រុនបក្សីនិងរោគគ្រុនផ្តាសាយធំ ក្រសួងសុខភាពនិងមនុស្សធម៌ សង្ឃឹមថា វាអាចជួយឲ្យយើងអាចរៀបចំត្រៀមខ្លួន-គឺ ពុំមែនបានន័យឲ្យយើងភ័យស្លន់ស្លោរនោះឡើយ។ មានមធ្យោបាយផ្សេងៗ ដែលសហគមន៍, គ្រួសារ, និងបុគ្គលម្នាក់ៗអាចអនុវត្ត ដើម្បីត្រៀមខ្លួនបាន។ លោកអ្នកអាចទិញម្ហូបអាហារនិងថ្នាំសង្កូវ សំរាំងទុក ក្រែងលោលោកអ្នកត្រូវ ជាប់នៅក្នុងផ្ទះ ពុំអាចចេញទៅណារួច។ លោកអ្នកអាចប្រើក្បួនអនាម័យ ដូចជា លាងដៃឲ្យបានញឹកញាប់, នៅផ្ទះកុំអញ្ជើញទៅណានៅពេលធ្លាក់ខ្លួនឈឺ។ មានពត៌មានជាច្រើនដែលលោកអ្នកអាចអានតាមរយៈវ៉ិបសៃ  www.pandemicflu.gov។

- ភាពយន្តនេះបានបង្ហាញឲ្យយើងឃើញនូវកត្តាខ្លះៗ ដែលអាចកើតមាន ប្រសិនបើមានមេរោគនេះកើតឡើង ដូចជា ការខ្វះខាតថ្នាំសំរាប់ចាក់បន្សាបមេរោគនិងថ្នាំបង្ការរោគក៏ដូចជាខ្វះខាតគ្រឿងឧបករណ៍, ថ្នាំពេទ្យនិងជំនួយផ្សេងៗទៀតផងដែរ។
- ម្យ៉ាងទៀត ភាពយន្តនេះបានបញ្ជាក់ឲ្យដឹងអំពីរយៈពេលដែលត្រូវចំណាយសំរាប់ធ្វើថ្នាំចាក់បង្ការរោគឲ្យមានប្រសិទ្ធិ។ ដូច្នេះហើយបានជាលោកប្រធានាធិបតិស្នើសុំឲ្យព្រឹទ្ធសភា យល់ព្រមផ្តល់ជំនួយឲ្យក្រសួងសុខភាពនិងមនុស្សធម៌នៃសហរដ្ឋចំណាយ ទៅលើការបង្កើនគុណភាពថ្នាំបង្ការរោគឲ្យមានប្រសិទ្ធិភាព។
- ខ្សែភាពយន្តបានបង្ហាញឲ្យដឹងសារសំខាន់ក្នុងការរៀបចំ ដើម្បីសហគមន៍មានស្ថេរភាពក្នុងកំឡុងពេលដែលមានការរាតត្បាតពីមេរោគគ្រុនបក្សី។ ក្រសួងសុខភាពនិងមនុស្សធម៌បានចង់ក្រងឯកសារសំរាប់អនុវត្ត ដោយមានរួមទាំងមធ្យោបាយដែលបុគ្គលិកម្នាក់ៗ, សហគមន៍នីមួយ, បុគ្គលិកសុខាភិបាល, សាលារៀន ,និងក្រសួងសហគមន៍ នានាត្រូវអនុវត។  ជំហ៊ានដែលត្រូវអនុវត្តមានរាយនៅក្នុងវិបសៃរបស់ក្រសួង នៅអាសយដ្ឋាន www.pandemicflu.gov។
- នៅពេលដែលមេរោគវីរើស H5N1 នៅពុំទាន់មានក្នុងសហរដ្ឋអាមេរិក រោគគ្រុនផ្តាសាយធំនៅពុំទាន់រាតត្បាតក្នុងពិភាពលោកនៅឡើយ ជាការមួយសំខាន់យើងគួរជ្រាបអំពីកត្តាដែលអាចនាំមកនូវផលវិបាកដល់សុខភាពសាធារណៈនិងជំហ៊ានដែលបុគ្គលម្នាក់ៗត្រូវយកមកអនុវត្ត ដើម្បីការពារខ្លួន, គ្រួសារ, និងសហគមន៍នៅដែលមានការរាតត្បាតនៃមេរោគ H5N1 នេះ។

ចំពោះសំណួរបន្ថែមស្ដីអំពីការពិតនៃរោគគ្រុនបក្សី សូមអានវិបសៃ www.pandemicflu.gov ឬពិភាក្សាជាមួយគ្រូពេទ្យប្រចាំកាយរបស់លោកអ្នក។

អត្ថបទនេះ ដកស្រង់ជាចំណែកពីសេចក្តីផ្សាយនៃក្រសួងសុខភាព និងមនុស្សធម៌នៃ សហរដ្ឋអាមេរិក (Department of Health and Human Services) ស្តីអំពីលក្ខណៈពីតនិងមិនពិតរបស់ខ្សែភាពយន "Fatal Contact: Bird Flu in America" និងបកប្រែដោយមណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល (http://abc.go.com/movies/birthflu.html) ។